ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**មាត្រា១៖**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ លើផ្ទៃដីសរុបចំនួន **១.០០០ហិកតា (មួយពាន់ហិកតា)** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកប្រាសាទបាល្ល័ង្ក និងស្រុកសណ្តាន់ ខេត្តកំពង់ធំ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ទេពី អាគ្រូ វិនិយោគ** (TEPI AGRO INVESTMENT CO., LTD) ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដាំដំណាំកៅស៊ូ ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ៨៦៣ សជណ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១១ ជាឧបសម្ព័ន្ធ។

www.pheakdeylaw.com

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "<u>ដើម្បីគោរពជូនជ្រាប</u>"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

បណ្ណាគារ ភក្តីឡង់
PheakdeyLaw Book Store

www.pheakdeylaw.com